ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៨៨

ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩

សាលដីកា

លេខ: ១៤ (I)

ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រមរបាយការណ៍

៥.លោកស្រី [redacted] ចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៤៥៣ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ[redacted]សុជាតិ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១២១ “ក្រ IV ណ” ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

### ជនជាប់ចោទ

ឈ្មោះ[redacted]សុជាតិ ភេទប្រុស អាយុ ៦០ឆ្នាំ ជាតិខ្មែរ មុខរបរ មន្ត្រីរាជការ ទីកន្លែងកំណើត នៅសង្កាត់លេខ៣ ក្រុងភ្នំពេញ រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន [redacted]ខណ្ឌកំពង់ស្ពឺ ឪពុក



Scanned with CamScanner

ឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូន០៦នាក់ ទោសពីមុនគ្មាន ។ (ក្រៅឃុំ) (សាទុក្ខ)

**ជាប់ចោទពីបទ:** ជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅភូមិទ្រា ឃុំញ្ញយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្ដន្ទាទោសតាមមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ។

**ដើមបណ្ដឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] សំអាត ភេទប្រុស អាយុ ៤២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិសំរោង ឃុំសំរោង ស្រុកបាទី ខេត្តតាកែវ ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូន ០៣នាក់ ជាទីតិជន។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ ភូមិទ្រា ឃុំញ្ញយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានករណីជេរប្រមាថជាសាធារណៈ មួយបានកើតដែលបង្កដោយឈ្មោះ [redacted] សុជាតិ ភេទប្រុស អាយុ៦០ឆ្នាំ បានជេរប្រមាថទៅលើឈ្មោះ [redacted] សំអាត តាមបណ្ដាញហ្វេសបុក។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៧៣ "ខ" ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ស្ពឺ មានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុជាតិ ភេទប្រុស អាយុ៦០ឆ្នាំ (ដែលមានសាវតាជាតិខាងលើ) ពិន័យជាប្រាក់ចំនួន ៤ ០០០ ០០០ (បួនលាន) រៀល ពីបទ ជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅភូមិទ្រា ឃុំញ្ញយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ។

២- បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សុជាតិ សងសំណងជំងឺចិត្តចំនួន ៤ ០០០ ០០០ (បួនលាន) រៀល ទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សំអាត នៅពេលសាលក្រមចូលជាស្ថាពរ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុជាតិ និងចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សំអាត បើកសិទ្ធិប្ដឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ១០៥ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] សុជាតិ គ្រង់ចំណុច នៃសាលក្រមទាំងមូល។



Scanned with CamScanner

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១២១ "ក្រ IV ណ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍លេខ ១០៤ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៧៣ "ខ" ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ស្ពឺ។

សាលដីកានេះ ធ្វើការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ កំបាំងមុខជនជាប់ចោទ ប្រកាសជាសាធារណៈ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ ទុកសិទ្ធិឲ្យប្ដឹងទាស់ និងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញ សារណាការពារចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុជាតិ ។

-បានឃើញ សារណាការពារចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សំអាត ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍។

-ក្រឡាបញ្ជីអានសារណាបញ្ជាក់ពីមូលហេតុនៃបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្ដីសន្និដ្ឋានសុំថា៖

-យល់ឃើញថា: រឿងនេះជនជាប់ចោទឈ្មោះ [redacted] សុជាតិ បានទទួលស្គាល់ថា ខ្លួនពិតជាបានប្រព្រឹត្តដូចដែលអយ្យការ និងតុលាការសម្រេចចោទប្រកាន់ និងផ្ដន្ទាទោសមែន។

ដូចនេះ បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ មិនមានមូលហេតុដូចក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។

## ហេតុដូច្នេះ

## តំណាងមហាអយ្យការប្ដឹងសុំចំពោះតុលាការកំពូលឲ្យ

១-ទទួលបណ្ដឹងសាទុក្ខលេខ ៤៥៣ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធ ដោយខុសទៅនឹងគតិច្បាប់។

២-តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ១២១ "ក្រ.IV.ណ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

Scanned with CamScanner

+ដើមបណ្តឹងរដ្ឋប្បវេណី [redacted] សំអាត ឆ្លើយថាក្នុងរឿងនេះខ្ញុំមិនដែលស្គាល់ហើយក៏ មិនដែលឃើញមុខឈ្មោះ [redacted] សុជាតិ នេះដែរ។ ហេតុអីបានជាគាត់ថាខ្ញុំជេរគាត់បើគាត់រកភស្តុតាងថា ខ្ញុំជេរគាត់មែនដាក់ទោសខ្ញុំមកចុះ ព្រោះខ្ញុំអត់ស្គាល់គាត់ទេ តើទៅជេរពីណា ។

ខ្ញុំបើកច្រកអោយគាត់សុំទោសខ្ញុំហេតុអីបានជាគាត់ ជេរខ្ញុំព្រោះឪពុកម្តាយខ្ញុំស្លាប់ហើយ ខ្ញុំប្តឹងអាជ្ញាធរអោយរកមើលអ្នកជេរខ្ញុំតើអ្នកណា ។

<u>សំណូមពរ:</u> សុំអោយគាត់សុំទោសខ្ញុំ សូមអោយតុលាការផ្តន្ទាទោសគាត់ទៅតាមច្បាប់ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់អំណានលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៥៣ ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទ [redacted] សុជាតិ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និង មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា តាមលិខិតបញ្ជាក់អំពី មូលហេតុនៃបណ្តឹងសាទុក្ខចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ របស់ដើមបណ្តឹងសាទុក្ខជាជនជាប់ចោទ [redacted] សុជាតិ ឃើញថា ពុំបានលើកឡើងអំពីបញ្ហាច្បាប់ដែលទាក់ទងទៅនឹងមូលហេតុនៃបណ្តឹងសាទុក្ខរបស់ខ្លួន ស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ប៉ុន្តែ ជនជាប់ចោទបានលើកឡើងតែអំពីប្រវត្តិនៃការងាររបស់ខ្លួន និង អង្គហេតុផ្សេងៗ ដែលពុំពាក់ព័ន្ធនឹងអង្គច្បាប់អាចឱ្យតុលាការកំពូល ពិចារណាតាមបញ្ញត្តិមាត្រា ៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានឡើយ ។ លើសពីនេះ ជនជាប់ចោទបានទទួលស្គាល់ក្នុងសារណារបស់ខ្លួន និង នៅក្នុងនីតិវិធីរបស់តុលាការអង្គហេតុថា ខ្លួនពិតជាបានជេរប្រមាថទៅលើដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈ facebook ដោយសារកំហឹងផ្តើមចេញមកពីដើមបណ្តឹងរដ្ឋប្បវេណីជេរប្រមាថជនជាប់ចោទមុន ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ពុំមានមូលហេតុស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

៣-យល់ឃើញថា ការលើកឡើងអំពីការជេរប្រមាថរបស់ដើមបណ្តឹងរដ្ឋប្បវេណីមកលើជនជាប់ចោទ និងសុំឱ្យតុលាការកំពូលសម្រេចលើការស្នើសុំដាក់បណ្តឹងតបចំពោះដើមបណ្តឹងរដ្ឋប្បវេណី ក៏មិនមែនមូលហេតុនៃបណ្តឹងសាទុក្ខ និង មិនមែនជាសមត្ថកិច្ចរបស់តុលាការកំពូលដែលត្រូវពិចារណា និងសម្រេចនោះទេ ។

Scanned with CamScanner

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១២១ ក្រIV "ណ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-បដិសេធ បណ្តឹងសាទុក្ខលេខ ៤៥៣ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទ [redacted] សុជាតិ ។

២-តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ១២១ ក្រIV"ណ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ ២០២០ និង ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ។

Scanned with CamScanner